**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តត្បូងឃ្មុំ**

សំណុំរឿងរដ្ឋប្បវេណីលេខ ៦៧

ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩

**សាលក្រមរដ្ឋប្បវេណី**

**លេខៈ** ១/៤៣ យ

ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០១៩

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តត្បូងឃ្មុំ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩។

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តត្បូងឃ្មុំ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តត្បូងឃ្មុំ

ដើមចោទឈ្មោះ [redacted] វ័ន្ទសាណែត ភេទស្រី អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ ដែលមានអាសយដ្ឋាន [redacted] ដោយមានកញ្ញាមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

ចុងចម្លើយឈ្មោះ [redacted] សិទ្ធី ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ ដែលមានអាសយដ្ឋានបច្ចុប្បន្ន [redacted]។

### អង្គហេតុ និងចំណុចវិវាទ

**១.ការទាមទាររបស់ដើមចោទ**

១. សុំលែងលះចុងចម្លើយឈ្មោះ [redacted] សិទ្ធី។

២. សុំសិទ្ធិគ្រប់គ្រងកូនឈ្មោះ [redacted] វឌ្ឍនៈ ភេទប្រុស អាយុ០៥។

៣. ប្រាក់ប្រដាប់ក្តីតុលាការជាបន្ទុករបស់ចុងចម្លើយ។

**២.ការពន្យល់ត្រួសៗអំពីរឿងក្តី**

២.១.ដើមចោទ និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍ទៅតាមប្រពៃណីតាំងពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៣ ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់ទេ។ នៅក្នុងការរួមរស់នៅជាមួយគ្នាដើមចោទ និងចុងចម្លើយ បានមានកូនប្រុសបង្កើតចំនួន០១នាក់ គឺឈ្មោះ [redacted] វឌ្ឍនៈ ភេទប្រុស កើតនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៤ ដែលបានចុះសំបុត្រកំណើតលេខ ១៧៨ ក្នុងសៀវភៅកំណើតលេខ ០៤/២០១៤ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៤ របស់មន្ត្រីអត្រានុកូលដ្ឋានសង្កាត់សួង។ ចំណែកឯទ្រព្យសម្បត្តិរួម គឺមិនមានអ្វីដែលត្រូវបែងចែកគ្នាទេ។

**២.២.**ចំណុចវិវាទៈ គ្មាន។

២.៣ ចំណុចគ្មានវិវាទ៖ ព្រមព្រៀងលែងលះគ្នា ,ប្រគល់កូនទៅឱ្យដើមចោទជាអ្នកគ្រប់គ្រងកូន។

២.៤.សេចក្ដីថ្លែងការណ៍របស់គូភាគី

-សេចក្ដីថ្លែងការណ៍របស់ដើមចោទ៖ នាងខ្ញុំ បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីជាមួយចុងចម្លើយតាំងពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៣ ប៉ុន្តែមិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ទេ។មូលហេតុដែលនាងខ្ញុំប្ដឹងសុំលែងលះពីចុងចម្លើយ ព្រោះរស់នៅមិនចុះសម្រុងនឹងគ្នា គំនិតខុសគ្នា ចរិកមានៈ ម្យ៉ាងទៀតចុងចម្លើយបានទៅធ្វើការនៅខេត្តរតនៈគិរី គ្មានពេលមករស់នៅជុំប្រពន្ធកូន ធ្វើឱ្យពួកយើងអស់មនោសញ្ចេតនាពីគ្នាបន្ដិចម្ដងៗ រហូតបានព្រមព្រៀងលែងលះគ្នាតែម្ដង។ចំពោះការគ្រប់គ្រង់កូននាងខ្ញុំសុំសិទ្ធិគ្រប់គ្រងកូនឈ្មោះ [redacted] វ័ន្ឋរ៉ៈ ព្រោះនាងខ្ញុំ អាចចិញ្ចឹម ថែរក្សា និងផ្ដត់ផ្គង់ការសិក្សារបស់កូនបាន។ ម្យ៉ាងទៀតកូនខាងលើ នៅតូចដែលត្រូវការមើលថែទាំពីនាងខ្ញុំ។

-សេចក្ដីថ្លែងការណ៍របស់ចុងចម្លើយ៖ ខ្ញុំបាទ យល់ព្រមលែងលះពីដើមចោទ និងប្រគល់សិទ្ធិឱ្យដើមចោទគ្រប់គ្រងកូនប្រុសឈ្មោះ [redacted] វ័ន្ឋរ៉ៈ។ ចំណែកឯ ទ្រព្យសម្បត្តិរួម ក៏ពួកយើងគ្មានអ្វីដែលត្រូវបែងចែកគ្នាទេ។ ខ្ញុំបាទ ទទួលស្គាល់ថាការរស់នៅជាប្ដីប្រពន្ធរបស់ពួកយើងពិតជាមិនសូវចុះសម្រុងនឹងគ្នាទេ គំនិតរបស់គាត់មានៈ មិនទទួលយកគំនិតរបស់ខ្ញុំ ម្យ៉ាងទៀតខ្ញុំបាទ រវល់ធ្វើការនៅខេត្តរតនៈគិរីដោយគ្មានពេលគ្រប់គ្រាន់សម្រាប់ជួបជុំគ្រួសារ ដូចនេះ ខ្ញុំបាទ ក៏យល់ព្រមលែងលះពីដើមចោទដែរ។ខ្ញុំបាទ យល់ព្រមឱ្យដើមចោទ ជាអ្នកគ្រប់គ្រងកូន ប៉ុន្តែខ្ញុំបាទ សុំសិទ្ធិទៅលេងកូន ឬ កូនមកលេងខ្ញុំ គ្រប់ពេល។

**-សេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ៖** ដោយហេតុថា ដើមចោទ និងចុងចម្លើយ បានព្រមព្រៀងគ្នាលែងលះ និងប្រគល់សិទ្ធិដើមចោទជាអ្នកមានអំណាចមេបាលើកូនប្រុស ឈ្មោះ [redacted] វ័ន្ឋរ៉ៈ ដូចនេះនាងខ្ញុំ ស្នើសុំឱ្យតុលាការសម្រេចទៅតាមការព្រមព្រៀងរបស់គូភាគី។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងពិនិត្យភស្ដុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា៖

១. ឈ្មោះ [redacted] **វ័ន្ធសាណែត** និងឈ្មោះ [redacted] **សិទ្ធី** ពិតជាបានរួមរស់នៅជាមួយគ្នាជាអនីតិសង្វាស ពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់ ដូចការអះអាងរបស់ភាគីទាំងពីរពិតប្រាកដមែន ។

២. ក្រោយពេលរួមរស់នៅមួយរយៈក្រោយ ដើមចោទនិងចុងចម្លើយរស់នៅមិនចុះសម្រុងគ្នា គំនិតខុសគ្នា ចរិកមានៈ ម្យ៉ាងទៀតចុងចម្លើយបានទៅធ្វើការនៅខេត្តរតនៈគិរី គ្មានពេលមករស់នៅជុំប្រពន្ធកូន ធ្វើឱ្យពួកយើង អស់មនោសញ្ចេតនាពីគ្នាបន្ដិចម្ដងៗ រហូតបានព្រមព្រៀងលែងលះគ្នាតែម្ដង នេះបញ្ជាក់ថាដើមចោទ និងចុងចម្លើយ ពិតជាអស់មនោសញ្ចេតនារួមរស់ជាមួយគ្នាជាអនីតិសង្វាសប្រាកដមែន។ ដើមចោទទាមទារឲ្យលែងលៈ តុលាការគប្បីមិនពិចារណាទេ ដោយដើមចោទ និងចុងចម្លើយពុំមានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់។ ដើមចោទ និងចុងចម្លើយ មានសេរីភាពរៀបអាពាហ៍ពិពាហ៍ថ្មីតាមឆន្ទៈរបស់ខ្លួនបាន។

៣. ក្នុងអំឡុងរស់នៅអនីតិសង្វាស គូភាគីមានកូនប្រុសបង្កើតចំនួនម្នាក់ ឈ្មោះ [redacted] វ័ន្ឋរ៉ៈ ភេទប្រុស កើតថ្ងៃទី [redacted] ដូចមានបញ្ជាក់ក្នុងសំបុត្រកំណើតលេខៈ ១៧៨ (សៀវភៅកំណើតលេខ០៤/២០១៤) ដែលចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៤ ពិតប្រាកដមែន។ ដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាកំណត់អ្នកមានអំណាចមេបាលើកូន ដោយឱ្យទៅឈ្មោះ [redacted] វ័ន្ធសាណែត

ហេតុនេះគប្បីតុលាការពិចារណាតាមឆន្ទៈព្រមព្រៀងរបស់គូភាគី ដូចមានចែងក្នុងមាត្រា១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

៥. ភាគីដើមចោទបានស្នើសុំបង់ប្រាក់ប្រដាប់ក្តីតុលាការ ហេតុនេះគប្បីតុលាការសម្រេចតាមការស្នើសុំនេះ។

## សេចក្តីសម្រេចបញ្ចប់

១. បញ្ចប់ការរស់នៅជាអនីតិសង្វាសរវាងដើមចោទឈ្មោះ [redacted] វ័ន្ទសាណែត និងចុងចម្លើយឈ្មោះ [redacted]សិទ្ធី ចាប់ពីពេលនេះតទៅ។ គូភាគីមានសេរីភាពរៀបអាពាហ៍ពិពាហ៍តាមឆន្ទៈរបស់ខ្លួនបាន។

២. កំណត់យកម្តាយឈ្មោះ [redacted] វ័ន្ទសាណែត ជាអ្នកមានអំណាចមេបាលើកូនប្រុសឈ្មោះ [redacted] វឌ្ឍនៈ ភេទប្រុស កើតថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៤ ដែលបានចុះសំបុត្រកំណើតលេខៈ ១៧៨ (សៀវភៅកំណើតលេខ០៤/២០១៤) ដែលចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៤។

ភាគីដែលពុំមានអំណាចមេបា មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន តាមពេលវេលាសមរម្យ។ ភាគីដែលមានអំណាចមេបាត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត ដើម្បីចូលជួបតាមបញ្ញត្តិមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី។

៣. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះ បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ និងចំពោះមុខចុងចម្លើយ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា៖ [redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃពុធ ៦រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២

ត្បូងឃ្មុំ,ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ត្បូងឃ្មុំ,ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩

**ចៅក្រមជំនុំជម្រះ**

[redacted]